ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៧៧៣ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតភូមិ នៃខេត្តក្រចេះ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋបាលខេត្តក្រចេះ

### សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត **ភូមិពោធិ៍** ដោយបំបែកចេញពីភូមិព្រែកតាអាំ នៃឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ។
ត្រូវបានបង្កើត **ភូមិ១០៥** ដោយបំបែកចេញពីភូមិទ្រាប នៃឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។
ត្រូវបានបង្កើត **ភូមិចំរើន** ដោយបំបែកចេញពីភូមិខ្នាច នៃឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិល្អ ភូមិត្រពាំងទ្រាំង** និង**ភូមិភ្នំដែកភ្លើង** ដោយបំបែកចេញពីភូមិកសាង នៃឃុំចង្រ្កង់ ស្រុកចិត្របុរី ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិអូរគគីរ** ដោយបំបែកចេញពីភូមិអញ្ចាញ នៃឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិអង្រ្កង** ដោយបំបែកចេញពីភូមិអន្ទង់វៀន នៃឃុំកន្ធួត ស្រុកចិត្របុរី ខេត្តក្រចេះ។

**ប្រការ ២.-**

ត្រូវបានបង្កើត **ភូមិដង្ហិត** ដោយបំបែកចេញពីភូមិប្រឡាយទ្រៀក នៃឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិបល្ល័ង្គ** ដោយបំបែកចេញពីភូមិស្រែទ្រៀក នៃឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិបុស្សខ្នុរ** ដោយបំបែកចេញពីភូមិព្រែកចំឡាក់ និងភូមិកញ្ជរ នៃឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិកំពង់ដំរីចាស់** និង**ភូមិច្រកដំបង** ដោយបំបែកចេញពីភូមិប្រម៉ា នៃឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិអូរទេវតា** ដោយបំបែកចេញពីភូមិវាលកន្សែង នៃឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ។

**ប្រការ ៣.-**

ត្រូវបានបង្កើត **ភូមិកាប៉ូ១** ដោយបំបែកចេញពីភូមិកាប៉ូ នៃសង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិអូរឫស្សី៣** ដោយបំបែកចេញពីភូមិអូរឫស្សី២ នៃសង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិស្រែស្តៅ១** ដោយបំបែកចេញពីភូមិស្រែស្តៅ នៃសង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ។

**ប្រការ ៤.-**

ត្រូវបានបង្កើត **ភូមិអូរកណ្តៀរ** និង**ភូមិភ្នំខៀវ** ដោយបំបែកចេញពីភូមិអូរព្រះ នៃឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិអូរអន្រ្លែង** និង**ភូមិសែនជ័យ** ដោយបំបែកចេញពីភូមិទោង នៃឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិបឹងចារ** ដោយបំបែកចេញពីភូមិដំរៃ នៃឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិឥន្ទជ័យ** ដោយបំបែកចេញពីភូមិកំពង់រទេះ នៃឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិត្រាំជុំ** ដោយបំបែកចេញពីភូមិវឌ្ឍនៈ និងភូមិតាងួន នៃឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ។

**ប្រការ ៥.-**

ត្រូវបានបង្កើត **ភូមិភ្វារង** ដោយបំបែកចេញពីភូមិជ្រោយបន្ទាយ នៃឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិអូរអង្គញ់** ដោយបំបែកចេញពីភូមិខ្សាច់ទប់ នៃឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិស្រុករទេះ ភូមិអូរគ្រញូង** និងភូមិត្រពាំងកកោះ ដោយបំបែកចេញពីភូមិទួលព្រិច នៃឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិបូសទឹក ភូមិកំពែង** និង**ភូមិអូរជ្រៃ** ដោយបំបែកចេញពីភូមិព្រែកប្រសព្វលើ នៃឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិតេជោសម្បទាន** ដោយបំបែកចេញពីភូមិស្ទឹងធំ នៃឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិអូរថ្មទោង ភូមិក្រឡាញ់ទ្រេត** និង**ភូមិស៊ីទែន** ដោយបំបែកចេញពីភូមិសោបក្រោម នៃឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

ត្រូវបានបង្កើត **ភូមិស្រែពពេល** ដោយបំបែកចេញពីភូមិព្រែកជីក នៃឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

**ប្រការ ៦.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលភូមិបង្កើតថ្មីដូចមានចែងនៅក្នុងប្រការ១ ប្រការ២ ប្រការ៣ ប្រការ៤ និងប្រការ៥ នៃប្រកាសនេះ ត្រូវអនុលោមទៅតាមសេចក្ដីណែនាំលេខ ០០៤ សណន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្ដីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្ដុភារនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តក្រចេះ គណៈអភិបាលខេត្តក្រចេះ ក្រុមប្រឹក្សាស្រុកចិត្របុរី ស្រុកឆ្លូង ក្រុងក្រចេះ ស្រុកសំបូរ និងស្រុកព្រែកប្រសព្វ គណៈអភិបាលស្រុកចិត្របុរី ស្រុកឆ្លូង ក្រុងក្រចេះ ស្រុកសំបូរ និងស្រុកព្រែកប្រសព្វ និងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១១រោច ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងផែនការ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារកាលប្បវត្តិ